# ជំពូកទី១ ៖ ទិដ្ឋភាពទូទៅនៃអំពើអនីត្យានុកូល

អំពើអនីត្យានុកូល គឺជារបបឲ្យសងការខូចខាត ក្នុងករណីដែលបានបំពាននូវសិទ្ធិ ឬ ផលប្រយោជន៍របស់អ្នកដទៃដោយខុសច្បាប់ដោយកំហុសចេតនា ឬអចេតនា ដូចនេះ បុគ្គលដែលមានសិទ្ធិ ឬផលប្រយោជន៍របស់ខ្លួនត្រូវបានបំពាន គឺមានសិទ្ធិទាមទារនូវសំណងនៃការខូចខាតចំពោះចារី ។

## ១. សញ្ញាណទូទៅអំពីអំពើអនីត្យានុកូល

ក្នុងករណីដែលមានអង្គហេតុមួយបានកើតឡើង រវាងភាគីដែលពុំមានទំនាក់ទំនងគតិយុត្តអ្វីមួយជាមុន ដូចជាទំនាក់ទំនងនៃកិច្ចសន្យា ជាដើម ហើយភាគីម្ខាងបានប្រព្រឹត្តអំពើអ្វីមួយ ដែលធ្វើឲ្យភាគីម្ខាងទៀតទទួលការខូចខាត គឺពិតជាពិបាកក្នុងការដោះស្រាយ ។ ដូចនេះបញ្ញត្តិស្តីពីអំពើអនីត្យានុកូល ត្រូវបានបង្កើតឡើងដើម្បីបញ្ជាក់អំពីអត្ថិភាពនៃដំណោះស្រាយ ដែលវាកំណត់អំពីការទទួលខុសត្រូវក្នុងការសងសំណងនៃការខូចខាតចំពោះជនរងគ្រោះ ត្រឹមកម្រិតណា និងក្រោមលក្ខខណ្ឌណាមួយ ។

### ក. និយមន័យ

យោងតាមសទ្ទានុក្រមនៃក្រមរដ្ឋប្បវេណី អំពើអនីត្យានុកូលសំដៅទៅលើអំពើដែលបំពានដោយខុសច្បាប់លើសិទ្ធិ ឬផលប្រយោជន៍អ្នកដទៃ ដោយកំហុសចេតនា ឬ អចេតនា ។ បន្ថែមលើនេះនៅក្នុងមាត្រា ៧៤២ ជំពូកទី១៦ (អំពើអនីត្យានុកូល) បានធ្វើការកំណត់ថា អំពើអនីត្យានុកូលសំដៅលើអំពើដែលបានប្រព្រឹត្តឡើងដោយមានកំហុសដោយចេតនា ឬ អចេតនា ហើយដែលអាចជាអំពើណាមួយដូចខាងក្រោម៖

ក. ធ្វើអំពើបំពានដោយព្យាករទុកជាមុនអំពីការកើតឡើងនៃលទ្ធផល ហើយទទួលយកការកកើតឡើងនៃលទ្ធផលនេះ ។

ខ. ធ្វើអំពើដែល បើតាមប្រក្រតី បុគ្គលដែលមានឋានៈនៃការងារ ឬបទពិសោធន៍ស្មើគ្នានឹងអ្នកធ្វើអំពើនេះ អាចព្យាករទុកជាមុនអំពីការកកើតនៃលទ្ធផលក៏ដោយ ក៏អ្នកធ្វើអំពើនោះនៅតែពុំបានព្យាករទុកជាមុនអំពើការកើតឡើងនៃលទ្ធផលនោះ ដោយសារការធ្វេសប្រហែសមិនប្រុងប្រយ័ត្ន ហើយទោះបីជាមានករណីយកិច្ចជៀសវាងនូវលទ្ធផលនោះក៏ដោយ ក៏នៅតែប្រព្រឹត្តផ្ទុយនឹងករណីយកិច្ចនោះ ។

អំពើអនីត្យនុកូល មានច្រើនបែបច្រើនយ៉ាង ហើយមិនត្រឹមតែជាគ្រោះថ្នាក់ ឬ ការបង្ខូចបរិស្ថាន ឬ កំហុសក្នុងការព្យាបាលនោះទេ គឺនៅមានការបំពានលើផលចំណេញ។

ក្នុងករណីដែលអំពើអនីត្យានុកូលបានបំពានទៅលើសិទ្ធិ ឬ ផលប្រយោជន៍របស់អ្នកដទៃដោយខុសច្បាប់ដោយកំហុសចេតនា ឬ អចេតនា ឬ អំពើអនីត្យានុកូល គឺមានន័យថា បុគ្គលម្នាក់ (ចារី) បានបង្កឲ្យមានការខូចខាតដោយខុសច្បាប់ទៅដល់បុគ្គលផ្សេងទៀត (ជនរងគ្រោះ) ដោយចេតនា និងអចេតនា ហើយនាំឲ្យមានការសងនូវសំណងនៃការខូចខាត ។ ដូច្នេះបុគ្គលដែលមានសិទ្ធិ ឬផលប្រយោជន៍របស់ខ្លួន ដែលត្រូវបានគេរំលោភបំពានមានសិទ្ធិទាមទារនូវសំណងការខូចខាត។ ម៉្យាងវិញទៀត កម្មវត្ថុនៃសំណងនៃការខូចខាតមិនត្រឹមតែមានការខូចខាតផ្នែកទ្រព្យសម្បត្តិប៉ុណ្ណោះទេ ប៉ុន្តែរួមមានទាំងការខូចខាតខាងផ្លូវចិត្តទៀតផង។

ឧទាហរណ៍ ៖ ក្នុងរឿងគ្រោះថ្នាក់ចរាចរណ៍មួយ បុគ្គល **ក** បានបើកឡានទៅបុកផ្ទះ **ខ** បណ្ដាលឲ្យបាក់ទ្វារផ្ទះ។ ដូចនេះ អំពើរបស់ **ក** ដែលបុកផ្ទះ **ខ** បណ្ដាលឲ្យមានការខូចខាតនោះ គឺជាអំពើអនីត្យានុកូល ហើយក្នុងរឿងនេះ **ខ** ក៏មានសិទ្ធទាមទារសំណងការខូចខាតពី **ក** វិញបាន។

**ខ. ទស្សនៈជាមូលដ្ឋាននៃអំពើអនីត្យានុកូល**

យើងដឹងហើយថា អំពើអនីត្យានុកូលតម្រូវឲ្យចារីសងសំណងការខូចខាតខាងសេដ្ឋកិច្ច និងខាងផ្លូវចិត្តចំពោះជនរងគ្រោះដើម្បីទទួលបាននូវយុត្តិធម៌។ ការទទួលខុសត្រូវលើអំពើអនីត្យានុកូលគឺយោងទៅតាម **គោលការណ៍នៃការទទួលខុសត្រូវកំហុស** មានន័យថានៅក្នុងសង្គមដែលមានសេរីភាព សេរីភាពខាងអំពើត្រូវបានធានា ។ បុគ្គលម្នាក់ៗជាគោលការណ៍មិនត្រូវទទួលខុសត្រូវនោះទេ ហើយបុគ្គលម្នាក់ៗត្រូវទទួលខុសត្រូវចំពោះលទ្ធផលដែលនឹងកើតមានឡើងពីសកម្មភាពដែលត្រូវបាន ឬ អាចត្រូវបានព្យាករទុកជាមុនបានក្នុងការបំពាននូវសិទ្ធិ ឬ ផលប្រយោជន៍របស់អ្នកដទៃ ។ ចំពោះសកម្មភាពដែលមិនអាចព្យាករដឹងបានពីលទ្ធផលនៃសកម្មភាពនោះជាទូទៅ ច្បាប់មិនតម្រូវឲ្យទទួលខុសត្រូវទេ ពីព្រោះវានឹងរារាំងដល់សកម្មភាពដោយសេរីទៅវិញ ។ ដូចនេះ ជាទូទៅគោលការណ៍នៃអំពើអនីត្យានុកូលគឺមិនតម្រូវឲ្យមានការទទួលខុសត្រូវទេទោះបី ជាមានការខូចខាតក៏ដោយ ប្រសិនបើអ្នកធ្វើសកម្មភាពនោះមិនធ្វើអំពើដោយមានកំហុសចេតនា ឬ អចេតនានោះ ។ តាមទស្សនៈនេះ ជនដែលបានធ្វើឲ្យអ្នកដទៃរងរបួសដោយគ្មានការប្រុងប្រយ័ត្នសមហេតុផលទេ ត្រូវទទួលខុសត្រូវចំពោះការរងរបួសនោះ ចំណែកឯគោលការណ៍នេះធ្វើឲ្យបុគ្គលម្នាក់ៗមុននឹងធ្វើអ្វីមួយ ត្រូវគិតពិចារណាឲ្យបានហ្មត់ចត់នូវសកម្មភាពរបស់ខ្លួនដើម្បីជៀសវាងនូវការកកើតឡើងនូវលទ្ធផលដែលអាចបង្កជាគ្រោះថ្នាក់ដល់អ្នកដទៃ[1]។

**២. លក្ខខណ្ឌនៃអំពើអនីត្យានុកូល**

យោងតាមមាត្រា ៧៤៣ លក្ខខណ្ឌនៃអំពើអនីត្យានុកូលទូទៅ គឺមានដូចខាងក្រោម ៖

[1] សៀវភៅ សេចក្តីពន្យល់ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បោះពុម្ពឆ្នាំ ២០១២ ភាគទី៤ ទំព័រ ១៨

- កំហុសចេតនា ឬអចេតនា
- ភាពខុសច្បាប់
- ការខូចខាត
- ទំនាក់ទំនងហេតុផល

**ក. កំហុសចេតនា ឬ អចេតនា**

កំហុសចេតនានៅក្នុងប្រព័ន្ធនៃអំពើអនីត្យានុកូលរបស់កម្ពុជា គឺជាការព្យាករទុកជាមុននូវហេតុការណ៍ និងការទទួលយកការកើតឡើងនៃលទ្ធផលនោះ។ ការដែលតម្រូវឲ្យមានចេតនា ឬកំហុស ធ្វើជាលក្ខខណ្ឌស្នូលនៃអំពើអនីត្យានុកូលបែបនេះ គឺជាគោលការណ៍ទទួលខុសត្រូវដោយផ្អែកលើកំហុស ក៏ប៉ុន្តែគោលការណ៍ទទួលខុសត្រូវដោយផ្អែកលើកំហុសនេះ គឺអនុលោមទៅតាមគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជនដែលជាគោលការណ៍ជាមូលដ្ឋានមួយនៃក្រមរដ្ឋប្បវេណី។

ក៏ប៉ុន្តែ បើផ្អែកទៅតាមការរីកចម្រើននៃវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ក៏ដូចជាឧស្សាហកម្ម វត្ថុដែលមានលក្ខណៈគ្រោះថ្នាក់រថយន្ត ជាដើម ដែលផ្តល់ការខូចខាតធ្ងន់ធ្ងរដល់អ្នកដទៃ ត្រូវបានផលិតយ៉ាងច្រើនសន្ធឹកសន្ធាប់ ហើយម្យ៉ាងវិញទៀត វាកើតមាននូវស្ថានភាពដែលអាចបង្កឲ្យមានការខូចខាតដែលមានវិសាលភាពធំធេង ។ ដោយសារតែមាននូវករណីជាច្រើនដែលជនរងគ្រោះមិនត្រូវបានសង្គ្រោះតាមគោលការណ៍ទទួលខុសត្រូវដោយផ្អែកលើកំហុស ទើបមានចំណោទបញ្ហាជាច្រើនកើតឡើងចំពោះគោលការណ៍នេះ។ ដោយហេតុនេះហើយទើបលេចចេញនូវទស្សនៈដែលថា បើទោះបីជាមិនមែនជាបញ្ហាអំពីចេតនា ឬកំហុសក៏ដោយ ក៏ត្រូវឲ្យមានការទទួលខុសត្រូវលើការខូចខាតដែរ ដោយសារតែផ្អែកលើមូលដ្ឋានថា ចារីបានបង្កឲ្យមានហានិភ័យដ៏ធំធេងទៅដល់សង្គម ឬ ដល់ជនរងគ្រោះ[2]។ ដូចនេះ នៅក្នុងក្រមរដ្ឋប្បវេណីបានបញ្ញត្តិអំពី កំហុសអចេតនាដែលជាការបំពានករណីយកិច្ចព្យាករទុកជាមុន និងករណីយកិច្ចជៀសវាង ហើយករណីយកិច្ចទាំងពីរនេះដាក់បន្ទុកលើភាគី តែនៅក្នុងករណីដែលការព្យាករទុកជាមុន និងការជៀសវាងអាចមានតែប៉ុណ្ណោះ (ច្បាប់មិនដែលចាប់បង្ខំភាពអលទ្ធភាពនោះទេ)។

**ខ. ភាពខុសច្បាប់**

ផ្អែកតាមមាត្រា ៧៤៣ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី បានចែងថា " បុគ្គលដែលបំពានដោយខុសច្បាប់នូវសិទ្ធិ ឬ ផលប្រយោជន៍របស់ជនដទៃ ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលកើតឡើងដោយអំពើនោះ"។ ការបំពាន

[2] សៀវភៅសេចក្តីផ្តើមនីតិរដ្ឋប្បវេណី បោះពុម្ពលើកទី៥ ភ្នំពេញ ឆ្នាំ ២០១១ ទំព័រ ១០៤

ដោយខុសច្បាប់មានន័យថា មិនត្រឹមតែបំពានទៅលើច្បាប់ព្រហ្មទណ្ឌ និងច្បាប់ផ្សេងៗប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអំពើផ្ទុយនឹងវិន័យសង្គម។

ជាទូទៅ ការបំពានដោយខុសច្បាប់នូវសិទ្ធិ ឬ ផលប្រយោជន៍ត្រឹមត្រូវរបស់អ្នកដទៃដោយកំហុសចេតនាក្តី ឬ កំហុសអចេតនាក្តី គឺជាអំពើផ្ទុយច្បាប់ ក៏ប៉ុន្តែប្រភេទនៃការបំពានមួយចំនួនមិនអាចចាត់ទុកថាផ្ទុយច្បាប់ទេ ។ ដូច្នេះមានករណីដែលការបំពានសិទ្ធិ ឬ ផលប្រយោជន៍របស់អ្នកដទៃមិនមែនជាអំពើផ្ទុយច្បាប់ទេ ។ មាត្រា ៧៥៦ នៃក្រមរដ្ឋប្បវេណី បានចែងអំពីមូលហេតុនៃការរួចផុតពីភាពផ្ទុយច្បាប់ ដែលកថាខណ្ឌទី ១ ចែងអំពី " ការយល់ព្រម និងការទទួលយកគ្រោះថ្នាក់ពីសំណាក់អ្នករងគ្រោះ " កថាខណ្ឌទី ២ ចែងអំពី " អំពើការពារធម្មានុរូប និងអំពើដោយសារស្ថានភាពចាំបាច់ " និងកថាខណ្ឌទី ៣ ចែងអំពី " អំពើដែលសង្គមទទួលស្គាល់ថាសមហេតុផល"។

**គ. ការខូចខាត**

ការខូចខាតត្រូវបានបែងចែកជាពីរគឺ[3] ៖

- ការខូចខាតដែលជាទ្រព្យសម្បត្តិ
- ការខូចខាតដែលជាមិនមែនជាទ្រព្យសម្បត្តិ

ការខូចខាតដែលជាទ្រព្យសម្បត្តិ ត្រូវបានបែងចែកជាពីរ ៖

សាហ៊ុយជាក់ស្តែង គឺជាសាហ៊ុយដែលជនរងគ្រោះមិនអាចជួយបង់បាន ដោយសារអំពើអនីត្យានុកូល ។

ការខូចខាតដែលមិនមែនជាទ្រព្យសម្បត្តិដែលជាញឹកញាប់បំផុត គឺការខូចខាតខាងផ្លូវចិត្តដែលតុលាការត្រូវធ្វើការវាយតម្លៃជាចំនួនទឹកប្រាក់ជាក់លាក់មួយចំនួន ។

ឧទាហរណ៍: បុគ្គល **ក** បានបើកបរដោយបង្កជាគ្រោះថ្នាក់ចរាចរណ៍ហើយបង្កការខូចខាតដល់បុគ្គល **ខ** ។ នោះយើងអាចកំណត់ថា អំពើនេះជាអំពើអនីត្យានុកូល ព្រោះថាវាជាអំពើដែលធ្វើឡើងដោយកំហុសអចេតនា និងបំពានករណីកិច្ចដែលច្បាប់តម្រូវឲ្យអ្នកបើកបរប្រុងប្រយ័ត្ននៅពេលបើកបរ ហើយវាបានបង្កការខូចខាតដល់អ្នកដទៃ ។ ការខូចខាតដល់បុគ្គល **ខ** អាចជាការខូចខាតជាទ្រព្យសម្បត្តិដូចជា ខូចខាតមធ្យោបាយធ្វើដំណើររបស់ **ខ** ហើយ **ខ** ត្រូវចំណាយលុយព្យាបាលខាតពេលវេលាធ្វើការ និងបាត់បង់ប្រាក់ចំណូល ។ ហើយក្នុងករណី **ខ** ទទួលមរណភាពគ្រួសាររបស់ **ខ** នឹងទទួលរងការខូចខាតខាងផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរទៀតផង ។

[3] សៀវភៅ សេចក្តីពន្យល់ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បោះពុម្ពឆ្នាំ ២០១២ ភាគទី៤ ទំព័រ ២៨

### ឃ. ទំនាក់ទំនងហេតុ និងផល

ដើម្បីឲ្យជនណាម្នាក់ទទួលខុសត្រូវសងសំណងការខូចខាត លុះត្រាតែមានទំនាក់ទំនងហេតុផលរវាង អំពើ និងការខូចខាតដែលបញ្ជាក់ថា ការខូចខាតនោះពិតជាកើតចេញពីអំពើអនីត្យានុកូលយ៉ាងពិតប្រាកដ ហើយដែលអ្នកទាមទារការខូចខាត មានករណីកិច្ចបញ្ជាក់អំពីភស្តុតាង។ ឧទាហរណ៍ ៖ **ក** បានប្តឹងទាមសំណងការខូចខាតពី **ខ** ដែលបានបង្ករបួសដល់ខ្លួន។ ក្នុងករណីនេះ **ក** ត្រូវធ្វើការបង្ហាញថា ឈ្មោះ **ខ** ជាអ្នកបានធ្វើឲ្យខ្លួនរងរបួស ហើយបណ្តាលឲ្យមានការខូចខាត ។ ម្យ៉ាងទៀត ការខូចខាត នឹងត្រូវបានសងក្នុងករណីដែលការខូចខាតនោះ មិនបានកើតឡើងទេ ប៉ុន្តែការខូចខាតនោះកើតឡើងដោយសារអំពើអនីត្យានុកូល ។

ទំនាក់ទំនងនៃហេតុផល មានន័យថាជាទំនាក់ទំនងនៃហេតុដែលជាលទ្ធផលនៃការកើតឡើងនូវការខូចខាចចំពោះជនរងគ្រោះ និងចេតនា ឬ អចេតនា កំហុសរបស់ចារី។ វាជារឿងធម្មតាទេ ដែលចាំបាច់ត្រូវតែមានអត្ថិភាពនៃទំនាក់ទំនងនៃហេតុផល ដើម្បីកំណត់ថា ចារីបានបង្កឲ្យមានការខូចខាតដល់ជនរងគ្រោះ[4]។

[4] សៀវភៅសេចក្តីផ្តើមនីតិរដ្ឋប្បវេណី បោះពុម្ពលើកទី៥ ភ្នំពេញ ឆ្នាំ ២០១១ ទំព័រ ១០៥

## ជំពូកទី២ ៖ ការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល

ការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល ត្រូវបានទទួលស្គាល់ថាជាការទទួលខុសត្រូវក្នុងការសងសំណងនៃការខូចខាត រវាងភាគីដែលពុំមានទំនាក់ទំនងគតិយុត្តជាមុន។

### ១. ការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលទូទៅ

ទម្រង់នៃការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលទូទៅ មិនមែនតម្រូវឲ្យមានតែការកើតឡើងនូវការខូចខាតតែប៉ុណ្ណោះទេ គឺតម្រូវឲ្យមានកំហុសចេតនា ឬ កំហុសអចេតនាថែមទៀត។ លក្ខខណ្ឌដែលតម្រូវឲ្យមានកំហុសចេតនា ឬ កំហុសអចេតនា អាចធានានូវសេរីភាពរបស់បុគ្គលឯកជន ព្រោះបុគ្គលម្នាក់មិនចាំបាច់ត្រូវទទួលខុសត្រូវចំពោះការខូចខាតទេ ទោះបីខ្លួនបានធ្វើឲ្យនរណាម្នាក់ទៀតរបួសក៏ដោយ ព្រោះខ្លួនបានធ្វើអំពើដោយប្រុងប្រយ័ត្នគ្រប់គ្រាន់ ហើយគ្មានកំហុសចេតនា ឬ កំហុសអចេតនានោះទេ។

ការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលទូទៅ គឺជាការទទួលខុសត្រូវចំពោះអំពើផ្ទាល់ខ្លួនដែលបានប្រព្រឹត្តទៅលើអ្នកដទៃ។ អំពើផ្ទាល់ខ្លួននោះ ត្រូវជាអំពើដែលបំពានដោយខុសច្បាប់នូវសិទ្ធិ ឬ ផលប្រយោជន៍របស់ជនដទៃ ដោយកំហុសចេតនា ឬអចេតនា ឬការមិនបានបំពេញករណីកិច្ចដែលខ្លួនត្រូវធ្វើ ។ ម្យ៉ាងទៀត អំពើអនីត្យានុកូលនោះ ត្រូវតែមានទំនាក់ទំនងហេតុផល រវាងអំពើរបស់អ្នកប្រព្រឹត្តអំពើបំពាន និងការកើតឡើងនៃការខូចខាត និងការខូចខាតដែលកើតឡើងលើជនរងគ្រោះ។[5] ឧទាហរណ៍: គ្រូពេទ្យម្នាក់ មិនបានបំពេញករណីកិច្ចរបស់ខ្លួន ដែលត្រូវព្យាបាលអ្នករបួសដែលមានសភាពធ្ងន់ធ្ងរឲ្យបានទាន់ពេលវេលា ហើយបណ្តោយឲ្យ ជនរងគ្រោះហូរឈាមរហូតដល់ស្លាប់បាត់បង់ជីវិត។ នេះក៏ជាអំពើអនីត្យានុកូលផងដែរ ព្រោះគ្រូពេទ្យនេះមិនបានបំពេញករណីកិច្ចរបស់ខ្លួនដែលត្រូវធ្វើ ហើយការស្លាប់របស់ជនរងគ្រោះ ពិតណាស់គឺមកពីអំពើរបស់គ្រូពេទ្យ ព្រោះតាមការអះអាងរបស់គ្រូពេទ្យជំនាញ ស្ថានភាពរបួសរបស់ជនរងគ្រោះមិនអាចបណ្តាលឲ្យជនរងគ្រោះស្លាប់នោះទេ បើគ្រូពេទ្យបានជួយសង្គ្រោះទាន់ពេលវេលា។ ដូចនេះ គ្រូពេទ្យដែលប្រព្រឹត្តអំពើអនីត្យានុកូលនោះ ត្រូវទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន។

### ២. ទម្រង់ពិសេសនៃអំពើអនីត្យានុកូល

ក្រៅពីអំពើអនីត្យានុកូលទូទៅ ក្រមរដ្ឋប្បវេណីបានបញ្ញត្តិពីទម្រង់មួយទៀតអំពីអំពើអនីត្យានុកូល ដែលជាទម្រង់ពិសេស។ ទាក់ទងទៅនឹងទម្រង់នេះ ក្រមរដ្ឋប្បវេណីគឺបានបញ្ញត្តិអំពើប្រធាន ឬ បុគ្គលដែលមានកាតព្វកិច្ចក្នុងការទទួលខុសត្រូវ ព្រមជាមួយនឹងលក្ខខណ្ឌនានាស្តីពីទម្រង់

---

[5] មាត្រា៧៤៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ពិសេសនៃអំពើអនីត្យានុកូលនេះ ។ ការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលទាំងអស់នេះអាច ហៅបានថា ជាការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលរបស់អ្នកដទៃ។

**ក. ការទទួលខុសត្រូវរបស់អ្នកដែលមានករណីយកិច្ចត្រួតពិនិត្យ**

ដូចមានចែងក្នុងក្រមរដ្ឋប្បវេណី អំពីជនមួយចំនួនដែលត្រូវបានកម្រិតសមត្ថភាព ដូចជា អនីតិជន(មាត្រា ១៧ ) ជននៅក្រោមអាណាព្យាបាលទូទៅ(មាត្រា២៤ ) និងជននៅក្រោមហិតូបត្ថម្ភ (មាត្រា ២៨ ) ដែលជនទាំងនេះត្រូវការជាចាំបាច់ឲ្យមានអ្នកគ្រប់គ្រង ឬ អ្នកតំណាងរបស់ខ្លួន ព្រោះថាពួកគេពុំមាន ឬ មានសមត្ថភាពតិចតួច ក្នុងការវិនិច្ឆ័យ ឬស្វែងយល់ពីសកម្មភាពរបស់ខ្លួន ឲ្យបានច្បាស់លាស់នោះទេ ។ ដូចនេះហើយទើបក្រមរដ្ឋប្បវេណីបានបញ្ញត្តិ អំពីការទទួលខុសត្រូវ ចំពោះអំពើទាំងឡាយណារបស់ជនដែលត្រូវបានកម្រិតសមត្ថភាព ដែលបានបង្កជាព្យាសនកម្ម ឬ ប៉ះពាល់ដល់អ្នកដទៃ ដោយអ្នកមានករណីយកិច្ចត្រួតពិនិត្យ ។ ជាក់ស្តែង នៅក្នុងមាត្រា ៧៤៦ នៃ ក្រមរដ្ឋប្បវេណី បានចែងអំពីអ្នកដែលមានករណីយកិច្ចត្រួតពិនិត្យ មានន័យថាអ្នកដែលច្បាប់បាន កំណត់ក្នុងការគ្រប់គ្រង ឬត្រួតពិនិត្យលើជនដែលត្រូវបានកម្រិតសមត្ថភាពទាំងនោះ ដូចជា អ្នក មានអំណាចមេបា អ្នកអាណាព្យាបាល អ្នកអាណាព្យាបាលទូទៅ និងហិតូបត្ថម្ភកៈ ដែលត្រូវទទួល ខុសត្រូវចំពោះអំពើដែលអ្នកស្ថិតក្រោមការគ្រប់គ្រងបានធ្វើហើយ និងបង្កឲ្យមានការខូតខាត ចំពោះអ្នកដទៃ ។ ឧទាហរណ៍ បុគ្គល ក ដែលជាអនីតិជនអាយុ១០ឆ្នាំ បានគប់ដុំថ្មលេង ហើយប ណ្តាលឲ្យបុគ្គល ខ មានរបួសដោយអចេតនា នោះអ្នកដែលមានអំណាចមេបា ឬ អ្នកអាណា ព្យាបាលរបស់បុគ្គល ក ត្រូវតែទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលរបស់បុគ្គល ក នេះ។

ទោះជាយ៉ាងណា ក៏មានអញ្ញត្រកម្មផងដែរចំពោះការទទួលខុសត្រូវរបស់អ្នកដែលមាន ករណីយកិច្ចត្រួតពិនិត្យដូចជា ចំពោះអនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ បើ ពួកគេបានប្រព្រឹត្តអំពើបំពានណាមួយដ៏អ្នកដទៃនោះ ត្រូវមានការទទួលខុសត្រូវដោយសាមគ្គីភាព រវាងអនីតិជននោះ និងអ្នកដែលមានករណីយកិច្ចត្រួតពិនិត្យ (មាត្រា៧៤៦ កថាខណ្ឌទី២)។ ម្យ៉ាង ទៀត ប្រសិនអ្នកដែលមានករណីកិច្ចត្រួតពិនិត្យ បានបញ្ជាក់ថាខ្លួនបានបំពេញករណីកិច្ចត្រួតពិនិ ត្យជាប្រក្រតី នោះអាចរួចផុតពីការទទួលខុសត្រូវក្នុងការសងការខូចខាតបាន (មាត្រា ៧៤៦ កថា ខណ្ឌទី៣) ។

**ខ. ការទទួលខុសត្រូវរបស់និយោជក**

និយោជក ជាអ្នកប្រើនិយោជិតឲ្យធ្វើសកម្មភាពណាមួយ ដើម្បីរកផលចំណេញឲ្យខ្លួន ហេតុ នេះហើយ ចំពោះអំពើអនីត្យានុកូលដែលបង្កឡើងដោយនិយោជិតក្នុងការអនុវត្តកិច្ចការ និយោជក ត្រូវទទួលខុសត្រូវជំនួសនិយោជិត។

យោងតាមមាត្រា ៧៤៧ លក្ខខណ្ឌនៃការទទួលខុសត្រូវរបស់និយោជក គឺមានដូចជា ៖

- បុគ្គលដែលត្រូវទទួលខុសត្រូវ អាចជានិយោជកដែលប្រើនិយោជិតដើម្បីអនុវត្តកិច្ចការ ឬ បុគ្គលដែលស្ថិតក្នុងឋានៈត្រូវត្រួតពិនិត្យនិយោជិតជំនួសនិយោជក។
- ការបង្កការខូចខាត កើតចេញសកម្មភាពអនុវត្តការងារ
- និយោជិតមានកំហុសចេតនា ឬអចេតនា

និយោជកត្រូវទទួលខុសត្រូវ ទោះបីជាខ្លួនគ្មានកំហុសក៏ដោយ នេះជាប្រភេទនៃការទទួលខុសត្រូវដែលមានលក្ខណៈតឹងតែង ។ មួយវិញទៀត អ្នកត្រួតពិនិត្យនិយោជិតជំនួសនិយោជក ក៏ត្រូវទទួលខុសត្រូវផងដែរ ប៉ុន្តែបើក្នុងករណីដែលបុគ្គលនោះបានត្រួតពិនិត្យត្រឹមត្រូវហើយ នោះអាចយកមកបញ្ជាក់ដើម្បីរួចផុតពីការទទួលខុសត្រូវចំពោះការខូតខាតនោះបាន (មាត្រា ៧៤៧ កថាខណ្ឌទី២)។ ឧទាហរណ៍: និយោជកបានប្រើនិយោជិតបំពេញកិច្ចការងារដោយដឹកជញ្ជូនទំនិញយកទៅឲ្យអតិថិជន។ ក៏ប៉ុន្តែក្នុងពេលដែលកំពុងធ្វើដំណើរតាមផ្លូវពីភ្នំពេញទៅកាន់ខេត្តព្រះសីហនុ ដើម្បីយកទំនិញទៅឲ្យអតិថិជននោះ ស្រាប់តែមានគ្រោះថ្នាក់ចរាចរណ៍ ដោយរថយន្តនោះបានជ្រុលទៅបុករថយន្តមួយទៀតដែលធ្វើដំណើរបញ្ច្រាសទិសគ្នា បណ្តាលឲ្យខូចខាតរថយន្តរបស់ភាគីម្ខាងទៀតនោះ។ ក្នុងករណីនេះនិយោជកត្រូវទទួលខុសត្រូវ ចំពោះអំពើដែលបានកើតឡើងចំពោះជនរងគ្រោះ ជំនួសនិយោជិត។

បើយោងទៅតាមកថាខណ្ឌទី ៣ នៃមាត្រា ៧៤៧ ឃើញថា និយោជក ឬអ្នកត្រួតពិនិត្យជំនួសនិយោជក អាចទាមទារសំណងពីនយោជិតបាន អាស្រ័យទៅតាមកម្រិតនៃកំហុសរបស់និយោជិតនោះ ។ យើងដឹងថា និយោជិតជាចារីផ្ទាល់ នោះត្រូវមានកាតព្វកិច្ចសងការខូតខាតរួមជាមួយនិយោជក ឬអ្នកត្រួតពិនិត្យជំនួសនិយោជក ប៉ុន្តែនិយោជក ឬអ្នកត្រួតពិនិត្យជំនួសនិយោជកមិនអាចទាមទារសំណងបានទេ ប្រសិនបើទំហំនៃកំហុសមានកម្រិតតិចតួច ។ ឧទាហរណ៍ ខាងលើដដែល ក្នុងករណីដែលនិយោជករកឃើញថា គ្រោះថ្នាក់នោះកើតឡើងដោយសារ ការធ្វេសប្រហែសក្នុងការបើកបររបស់និយោជិត នោះនិយោជកអាចទាមទារឲ្យនិយោជិត ជួយចេញសំណងនៃការខូចខាតតាមកម្រិតកំហុស។

**គ. អំពើអនីត្យានុកូលរបស់នីតិបុគ្គល**

ទាក់ទងនិងការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលរបស់នីតិបុគ្គលនេះដែរ បើយោងទៅតាមមាត្រា ៧៤៨ នៃក្រមរដ្ឋប្បវេណី ឃើញថាមានលក្ខណៈប្រហាក់ប្រហែលទៅនិងបញ្ញត្តិនៃការទទួលខុសត្រូវរបស់និយោកជកផងដែរ ព្រោះថាវាស្ថិតក្នុងស្ថានភាពមួយដូចគ្នាដែលកើតចេញពី

បុគ្គលដែលធ្វើការនៅក្នុងរោងចក្រសហគ្រាស ឬក្រុមហ៊ុនណាមួយ ។ ប៉ុន្តែវាមានភាពខុសគ្នា មួយចំនួនដូចជា ៖

- ក្នុងករណីអំពើអនីត្យានុកូលរបស់នីតិបុគ្គល អ្នកប្រព្រឹត្តអំពើបំពានគឺត្រូវបានកម្រិតចំពោះសមាជិកនាយក ឬ អ្នកតំណាងស្របច្បាប់របស់នីតិបុគ្គលនោះ ចំណែកក្នុងករណីនៃការទទួលខុសត្រូវរបស់និយោជក គ្មានការកំណត់បែបនេះទេ តែជាការទទួលខុសត្រូវរបស់រូបវន្តបុគ្គលម្នាក់ដែលជានិយោជក ចំពោះអំពើរបស់រូបវន្តបុគ្គលម្នាក់ទៀតដែលជានិយោជិត។
- នីតិបុគ្គលមិនអាចធ្វើការតវ៉ា ដើម្បីរួចផុតពីការទទួលខុសត្រូវ ដូចជាការតវ៉ានៅក្នុងករណីនៃការទទួលខុសត្រូវរបស់បុគ្គលដែលត្រួតពិនិត្យជំនួសនិយោជក ដោយអះអាងពីការគ្រប់គ្រងត្រឹមត្រូវបានឡើយ ។

ចំពោះអំពើអនីត្យានុកូលដែលបានប្រព្រឹត្តដោយអ្នកតំណាងរបស់នីតិបុគ្គល គឺសាមីខ្លួនអ្នកតំណាងនោះជាអ្នកទទួលខុសត្រូវ ហើយក្រៅពីនេះនីតិបុគ្គលក៏ត្រូវទទួលខុសត្រូវផងដែរ។ ពាក់ព័ន្ធនឹងការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលរបស់នីតិបុគ្គលពុំមានបញ្ញត្តិលើកលែង ដូចការទទួលខុសត្រូវរបស់និយោជកទេ ពោលគឺមានភាពតឹងតែងជាង ដោយហេតុថាទំនាក់ទំនងរវាងអ្នកតំណាងនឹងនីតិបុគ្គល គឺមានភាពជិតស្និទ្ធណាស់ ។ លើសពីនេះទៅទៀតអំពើរបស់ស្ថាប័នតំណាងគឺជាអំពើរបស់នីតិបុគ្គលនោះតែម្តង ។ ឧទាហរណ៍: អ្នកតំណាងក្រុមហ៊ុន ក ម្នាក់បានធ្វើសកម្មភាពអនុវត្តភារកិច្ច ដោយចុះកិច្ចសន្យាមួយដែលក្នុងនាមបម្រើផលប្រយោជន៍ឲ្យក្រុមហ៊ុន តែកិច្ចសន្យានោះបែរជាមានផលប៉ះពាល់ដល់ផលប្រយោជន៍របស់បុគ្គលដែលជាភាគីនៃកិច្ចសន្យាដោយខុសច្បាប់ ដែលទាមទារឲ្យមានការទទួលខុសត្រូវសងការខូចខាតដល់ភាគីរងគ្រោះ។ ក្នុងករណីនេះ នីតិបុគ្គល ពោលគឺក្រុមហ៊ុនត្រូវទទួលខុសត្រូវចំពោះអំពើរបស់អ្នកតំណាងនោះជាដាច់ខាត ដោយមិនអាចលើកឡើងនូវហេតុផលដើម្បីរួចផុតពីការទទួលខុសត្រូវឡើយ។ ទោះជាយ៉ាងណា នីតិបុគ្គលអាចទាមទារសំណងពីអ្នកតំណាងដែលបានប្រព្រឹត្តអំពើបង្កការខូច ខាតនោះបាន បើយោងតាមកថាខណ្ឌ២ នៃមាត្រា៧៤៨ នៃក្រមរដ្ឋប្បវេណី។

### ឃ. អំពើអនីត្យានុកូលរបស់មន្ត្រីរាជការ

ជាបញ្ញត្តិមួយថ្មី ដែលបង្ហាញពីសមភាពរវាងរដ្ឋ និងប្រជាពលរដ្ឋ ដោយសារតែរដ្ឋគឺមាននូវអំណាចមួយដែលហៅថា បុព្វសិទ្ធិនៃអំណាចសាធារណៈ ដែលនៅក្នុងន័យនេះគឺគ្មានទេសមភាពរវាងរដ្ឋ និងប្រជាពលរដ្ឋនោះ។ ប៉ុន្តែក្នុងទិដ្ឋភាពនេះមិនមានន័យថាប្រជាពលរដ្ឋត្រូវតែមាន

សមភាពជាមួយរដ្ឋគ្រប់កាលៈទេសៈនោះទេ គឺថាប្រជាពលរដ្ឋមានសិទ្ធិប្តឹងទាមទារសំណងការខូតខាតពីរដ្ឋបានដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ (មាត្រា ៣៩) តែប៉ុណ្ណោះ។

ដោយអនុលោមទៅតាមស្មារតីនៃរដ្ឋធម្មនុញ្ញ ទើបក្រមរដ្ឋប្បវេណី ត្រង់មាត្រា ៧៤៩ បានបញ្ញត្តិ អំពីអនីត្យានុកូលរបស់មន្ត្រីរាជការ និងបញ្ជាក់អំពីលក្ខខណ្ឌដូចជា ៖

- បុគ្គលប្រព្រឹត្តអំពើអនីត្យានុកូលត្រូវជាមន្ត្រីរាជការ
- ប្រព្រឹត្តអំពើក្នុងពេលទទួលនូវការអនុវត្តអំណាចសាធារណៈ ជាលក្ខខណ្ឌមួយដែលតម្រូវឲ្យមានជាដាច់ខាត ដូចនេះសកម្មភាពឯកជនរបស់មន្ត្រីរាជការមិនបណ្តាលឲ្យមានការទទួលខុសត្រូវរបស់រដ្ឋ ។
- បង្កការខូចខាតដល់អ្នកដទៃដោយខុសច្បាប់ ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា

យោងតាមមាត្រា ៧៤៩ កថាខណ្ឌទី១ មន្ត្រីសាធារណៈផ្ទាល់មិនទទួលខុសត្រូវចំពោះអំពើបំពានទេ ប៉ុន្តែមានតែរដ្ឋប៉ុណ្ណោះ ដែលត្រូវទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល នៅពេលអនុវត្តនូវអំណាចសាធារណៈរបស់រដ្ឋ ឬស្ថាប័នសាធារណៈ ។ រដ្ឋ ឬ ស្ថាប័នសាធារណៈ អាចទាមទារសំណងបានតែនៅពេលដែលមន្ត្រីរាជការបានបំពានករណីយកិច្ចធ្ងន់ធ្ងរ (មាត្រា ៧៤៩ កថាខណ្ឌទី២)។ ចំពោះចំណុចខុសគ្នាទៅនឹងការទទួលខុសត្រូវរបស់និយោជក គឺពុំមានបញ្ញត្តិលើកលែងសម្រាប់រដ្ឋ ឬអង្គការសង្គមដើម្បីរួចផុតពីការទទួលខុសត្រូវនោះទេ ហើយការទាមទារសំណងដោយរដ្ឋ ឬដោយអង្គការសង្គមចំពោះសាមីខ្លួនជាមន្ត្រីរាជការអាចធ្វើទៅបាន តែក្នុងករណីដែលមានការធ្វើសកម្មភាពផ្ទុយនឹងករណីយកិច្ចធ្ងន់ធ្ងរតែប៉ុណ្ណោះ។

ឧទាហរណ៍ៈ កម្លាំងមានសមត្ថកិច្ច ទទួលបានអំណាចបង្ក្រាបបទល្មើសដែលកើតមាន ក៏ប៉ុន្តែក្នុងពេលអនុវត្តភារកិច្ចនោះ ដោយមានការប្រើប្រាស់កម្លាំងបាញ់ប្រឆាំងនឹងការបង្ក្រាប របស់សមត្ថកិច្ចពីសំណាក់ជនល្មើស សមត្ថកិច្ចក៏សម្រេចប្រើប្រាស់កម្លាំងដើម្បីទប់ទល់នឹង ជនល្មើសវិញ។ ក្នុងខណៈដែលសមត្ថកិច្ចសម្រេចប្រើប្រាស់អាវុធ ស្រាប់តែគ្រាប់កាំភ្លើងរបស់ សមត្ថកិច្ចម្នាក់បានផ្លាតទៅត្រូវប្រជាពលរដ្ឋម្នាក់បណ្តាលឲ្យរងរបួស។ ដូចនេះ ស្ថាប័នដែលជាអ្នក តំណាងឲ្យសមត្ថកិច្ចនេះ ត្រូវទទួលខុសត្រូវចំពោះអំពើរបស់មន្ត្រីនោះដែលបានបង្កការខូចខាត ដល់ជនរងគ្រោះ។ ទោះជាយ៉ាងនេះ ប្រសិនបើរកឃើញថា សមត្ថកិច្ចនោះបានបំពានករណីយកិច្ច ជៀសវាងនូវការបង្កការខូចខាតធ្ងន់ធ្ងរ ដោយធ្វើការបាញ់តបតជាមួយជនល្មើសក្នុងទីប្រជុំជននោះ ស្ថាប័នតំណាងមន្ត្រីនោះ អាចទាមទារសំណងពីមន្ត្រីនោះបាន។

## ង. ការទទួលខុសត្រូវរបស់អ្នកកាន់កាប់សត្វ

យោងតាមមាត្រា ៧៥០ នៃក្រមរដ្ឋប្បវេណី មិនបានបង្ហាញពីកំហុស (ចេតនា ឬអចេតនា) របស់អ្នកកាន់កាប់សត្វនោះទេ ដូចនេះ អ្នកកាន់កាប់សត្វត្រូវទទួលខុសត្រូវក្នុងការសងការខូតខាត ប្រសិនបើមាន ទោះជានៅពេលដែលអ្នកកាន់កាប់នោះ បានបង្ហាញថាខ្លួនបានគ្រប់គ្រងដោយត្រឹមត្រូវ និងគ្មានកំហុសក៏ដោយ ។ ចំពោះលក្ខខណ្ឌនៃការទទួលខុសត្រូវរបស់អ្នកកាន់កាប់នេះទៀតសោត គឺត្រូវតែជាអ្នកកាន់កាប់សត្វដែលបានបណ្តាលឲ្យមានការខូចខាតដល់អ្នកដទៃ ព្រមទាំងទំនាក់ទំនងរវាងហេតុ និងផលជាចាំបាច់ ទើបអាចនាំឲ្យមានការទទួលខុសត្រូវ ។ ការពិចារណាលើលក្ខខណ្ឌចំពោះអ្នកកាន់កាប់សត្វ គឺមិនចាំបាច់ថាអ្នកកាន់កាប់សត្វនោះមានកំហុស ឬគ្មានកំហុសនោះទេ មានន័យថា អ្នកកាន់កាប់ត្រូវតែទទួលខុសត្រូវដោយគ្មានកំហុស ដែលមិនអាចមានការអនុគ្រោះឲ្យរួចផុតពីកាទទួលខុសត្រូវទេ ។ ឧទាហរណ៍ ការបណ្តែតបណ្តោយឲ្យសត្វគោរបស់ខ្លួនដើរពាលវាលលើថ្នល់ ហើយសត្វបង្កឲ្យអ្នកដទៃមានគ្រោះថ្នាក់ចរាចរណ៍រងរបួសជាដើម។

## ច. ការទទួលខុសត្រូវចំពោះផលិតផលរបស់អ្នកផលិតវត្ថុ

តាមក្រមរដ្ឋប្បវេណី មាត្រា ១១៩ បានផ្តល់និយមន័យលើវត្ថុ ថា គឺសំដៅលើរបស់ដែលមានរូបរាងជាសារធាតុឧស្ម័ន ជាសារធាតុរាវ និងសាធាតុរឹង។ វត្ថុអាចជាចលនវត្ថុ និងអចលវត្ថុ។ ដោយសារវត្ថុទាំងនេះអាចប៉ះពាល់ដល់មនុស្ស ដែលកើតចេញពីអ្នកគ្រប់គ្រង ឬអ្នកផលិតវត្ថុទាំងនោះ ដូចនេះហើយទើបមាត្រា ៧៥១ នៃក្រមរដ្ឋប្បវេណីបានបញ្ញត្តិអំពីការទទួលខុសត្រូវចំពោះផលិតផលរបស់អ្នកផលិតវត្ថុនោះ ។ ចំពោះការទទួលខុសត្រូវរបស់អ្នកផលិតវត្ថុនោះ ត្រូវតែកើតចេញពី ការមានវិការៈនាំឲ្យមានគ្រោះថ្នាក់មិនសមហេតុផល និងបណ្តាលឲ្យការខូចខាតដល់អ្នកដទៃ ។

យោងតាមមាត្រា ៧៥១ អ្នកដែលត្រូវបានកំណត់ថាត្រូវទទួលខុសត្រូវរួមមាន ៖

- អ្នកដែលផលិតចលនវត្ថុដែលផ្សំដោយគ្រឿង ឬ វត្ថុធាតុដើមដែលមានវិការៈ
- អ្នកនាំចូល
- បុគ្គលដែលបានដាក់សញ្ញានៃនាមករណ៍របស់ខ្លួននៅលើចលនវត្ថុ ក៏ត្រូវចាត់ទុកថាជាអ្នកផលិតដែរ ហើយត្រូវទទួលខុសត្រូវផងដែរ

ក្នុងករណីដែលអ្នកប្រើប្រាស់ ឬអ្នកបរិភោគ ឬអ្នកដទៃទៀត មានការខូចខាតដោយសារតែទំនិញ (ផលិតផល) ដែលអ្នកផលិតបានលក់ មានវិការៈ អ្នកផលិតត្រូវទទួលខុសត្រូវនូវសំណងនៃការខូចខាតនោះ។ បន្ថែមលើនេះអ្នកដែលប្រើប្រាស់នូវផលិតផលដែលមានវិការៈនោះអាចទាមទារឲ្យអ្នកផលិតទទួលខុសត្រូវ ដោយគ្រាន់តែបញ្ជាក់ភស្តុតាងអំពីវិការៈប៉ុណ្ណោះ គឺមិនចាំបាច់បញ្ជាក់

ភស្តុតាង ថាអ្នកផលិតមានកំហុសនោះទេ ។ ឧទាហរណ៍: ផលិតករផ្ទាល់ ឬអ្នកដែលត្រូវចាត់ទុកជាផលិតករ ត្រូវទទួលខុសត្រូវចំពោះផលិតផលរបស់ខ្លួន ដែលមានផ្ទុកទៅ ដោយសារធាតុដែលប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពរបស់អ្នកប្រើប្រាស់។ ប៉ុន្តែបញ្ញត្តិ ការទាមទារនេះ មិនអាចធ្វើបានទេ ចំពោះករណីដែលមិនអាចប្រមាណនូវវិការៈនោះ តាមកម្រិតវិទ្យាសាស្ត្រ នៃបច្ចេកទេសដែលមាននៅក្នុងសម័យដែលផលិតនោះ (មាត្រា ៧៥១ កថាខណ្ឌទី១) ។

**ឆ. ការទទួលខុសត្រូវចំពោះវត្ថុគ្រោះថ្នាក់**

បើពិនិត្យតាមមាត្រា ៧៥២ យើងឃើញថា វត្ថុដែលមានកំណត់នៅក្នុងចំនុចនេះសុទ្ធសឹងតែជាប្រភេទវត្ថុដែលមានអត្រាគ្រោះថ្នាក់ខ្ពស់ដូចជា គ្រឿងផ្ទុះ វត្ថុធាតុវិទ្យុសកម្ម វត្ថុធាតុគីមីដែលមានជាតិពុល អតិសុខុមប្រាណឧត្បាត ឬ គ្រឿងដែលមានកម្រិតគ្រោះថ្នាក់ ផ្សេងទៀត ឬរថយន្តនិងគ្រឿងចក្រសម្រាប់ដឹកជញ្ជូនផ្សេងៗ។ ដូចនេះទាមទារឲ្យមានការគ្រប់គ្រងឲ្យបានហ្មត់ចត់។ ដូចនេះ ប្រសិនបើវត្ថុទាំងនោះបានបង្កឲ្យមានការខូតខាតដល់អ្នកដទៃ នោះកម្មសិទ្ធិករត្រូវទទួលខុសត្រូវក្នុងការសងការខូតខាតទាំងនោះ ដែលកើតចេញពីកំហុសរបស់ខ្លួន ។ ឧទាហរណ៍: រោងចក្រនុយក្លេអ៊ែរមួយកន្លែង បានធ្លាយធាតុវិទ្យុសកម្មតាមបំពង់ ដែលធ្វើឲ្យ ប៉ះពាល់ដល់សុខភាពរបស់ប្រជាពលរដ្ឋដែលនៅក្បែរនោះយ៉ាងធ្ងន់ធ្ងរ។ ដូចនេះ ម្ចាស់កម្មសិទ្ធិ រោងចក្រនោះ ត្រូវទទួលខុសត្រូវចំពោះសំណងខូចខាតដល់ជនរងគ្រោះទាំងអស់។

ប៉ុន្តែកម្មសិទ្ធិករក៏មានសិទ្ធិក្នុងការតវ៉ាក្នុងការមិនទទួលខុសត្រូវបានដែរ ក្នុងករណី ប្រធានសក្តិ ការគ្រប់គ្រងវត្ថុដោយគ្មានវិការៈ ហើយការខូចខាតបណ្តាលមកពីអំពើរបស់ជនរងគ្រោះ ឬតតិយជន។ ឧទាហរណ៍ករណីខាងលើដដែល បើការលេចធ្លាយធាតុវិទ្យុសកម្មនោះ បណ្តាលមកពីគ្រោះ ធម្មជាតិធ្ងន់ធ្ងរដែលមិនអាចទប់ស្កាត់បាន ហើយខ្លួនបានគ្រប់គ្រងដោយត្រឹមត្រូវ និងព្យាយាមធ្វើ គ្រប់បែបយ៉ាងដើម្បីជៀសវាងបង្កផលប៉ះពាល់ហើយនោះ នោះកម្មសិទ្ធិករអាចរួចផុតពីការទទួល ខុសត្រូវបាន។

**ជ. ការទទួលខុសត្រូវចំពោះសំណង់ជាប់នឹងដី**

នេះជាចំនុចមួយសំខាន់ផងដែរ ដែលកំណត់ពីផលវិបាកនានាទាក់ទងនិងការគ្រប់គ្រងសំណង់ដែលជាប់នឹងដី ក្នុងករណីសំណង់នោះបានបង្កការខូចខាត ឬប៉ះពាល់ដល់ផលប្រយោជន៍របស់អ្នកដទៃ ។ ហេតុនេះហើយមាត្រា ៧៥៣ បានបញ្ញត្តិអំពីបញ្ហាទាំងនេះ ចំពោះវិការៈដែលកើតចេញពីសំណង់ដែលជាប់នឹងដីនោះ ហើយត្រូវមានការទទួលខុសត្រូវចំពោះការខូតខាតទាំងឡាយពីកម្មសិទ្ធិករ និងអ្នកគ្រប់គ្រងសំណង់នោះដោយសាមគ្គីដែលត្រូវកណត់ទៅតាមកម្រិតនៃការបង្កឲ្យមានវិការៈនៃការសាងសង់ ឬគ្រប់គ្រង(កថាខណ្ឌទី២) ។ ឧទាហរណ៍:អាគារពាណិជ្ជកម្ម ដែល

មានកម្ពស់៤០ ជាន់មួយកន្លែងបានបង្កការខូចខាតដល់អ្នកដទៃ ក្នុងពេលកំពុងសាងសង់ ពោលគឺមានការធ្លាក់នូវបំណែកកញ្ចក់នៃអាគារមកលើអ្នកធ្វើដំណើរក្បែរនោះ បណ្តាលឲ្យមាន របួសធ្ងន់។ ដូចនេះ ទាំងម្ចាស់អាគារ និងអ្នកគ្រប់គ្រងការសាងសង់ត្រូវទទួលខុសត្រូវសងការខូចខាតដល់ជនរងគ្រោះដោយសាមគ្គី។ ប៉ុន្តែអ្នកគ្រប់គ្រងអាចរួចផុតពីការទទួលខុសត្រូវបានកាលណាមានភស្តុតាងបញ្ជាក់ថាខ្លួនបានធ្វើការគ្រប់គ្រងដោយត្រឹមត្រូវ(មាត្រា ៧៥៣ កថាខណ្ឌទី១) ។

**ឈ. អំពើអនីត្យានុកូលរួម**

បញ្ញត្តិនេះមានចែងក្នុងមាត្រា ៧៥៤ ប្រសិនបើការខូតខាតដែលបានកើតឡើងដោយសារអំពើរបស់បុគ្គលច្រើននាក់រួមគ្នា អ្នកប្រព្រឹត្តិអំពើនីមួយៗ ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដោយសាមគ្គីភាព។ ចំពោះទំហំនៃសំណងសងការខូចខាតវិញ បើសិនជាអំពើរួមគ្នាពាក់ព័ន្ធជិតស្និតដូចជាករណីនៃការសមគំនិតគ្នា ជាដើម ចារីម្នាក់ៗ ត្រូវទទួលខុសត្រូវដោយសាមគ្គីភាពនូវសំណងនៃការខូចខាតទាំងទាំងអស់។ ក្នុងករណីដែលទំនាក់ទំនង មិនសូវជិតស្និតទេអ្នកប្រព្រឹត្តអំពើបំពាន អាចទទួលខុសត្រូវក្នុងការសងការខូចខាតតាមសមាមាត្រនៃភាគដែលខ្លួនបានបង្ក។ សូមសំគាល់ថា សូម្បីតែនៅក្នុងករណីដែលគ្មានទំនាក់ទំនងជិតស្និត ប៉ុន្តែអ្នកប្រព្រឹត្តអំពើបំពានមិនអាចបញ្ជាក់អំពីភាគនៃអំពើដែលខ្លួនបានបង្កឲ្យមានការខូចខាត ជននោះមិនអាចរួចផុតពីការទទួលខុសត្រូវក្នុងការសងការខូចខាតទាំងអស់បានទេ។ ប្រសិនបើ ជនម្នាក់ក្នុងចំណោមអ្នកប្រព្រឹត្តបានសងការខូចខាតទាំងអស់ដោយចេញចំណាយរបស់ខ្លួន ជននោះអាចទាមទារ សំណងពីអ្នកផ្សេងទៀតដែលបានចូលរួមប្រព្រឹត្តអំពើអនីត្យនុកូលនោះបាន តាមសមាមាត្រាដែលជនម្នាក់ៗបានបង្ក។

**៣. មូលហេតុនៃការមិនទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល**

ទោះបីជាមានការខូតខាតកើតឡើងក៏ដោយ ក៏មិនតម្រូវឲ្យមានការទទួលខុសត្រូវឡើយ បើការខូចខាតនោះកើតឡើងក្នុងករណីដូចជា ៖

**ក. ការរួចផុតពីភាពផ្ទុយច្បាប់**

ការការពារធម្មានុរូប សំដៅលើអំពើរំលោភដែលពុំអាចជៀសវាងបានដើម្បីការពាររូបរាងកាយ ឬទ្រព្យសម្បត្តិ ឬអ្នកដទៃចំពោះអំពើបំពានមិនត្រឹមត្រូវ ហើយដែលស្ថិតនៅក្នុងករណីដែលអំពើបំពាន និងអំពើរំលោភស្ថិតនៅជិតគ្នា មានតុល្យភាពរវាងវិធីការពារ និងកម្រិតនៃអំពើបំពាននោះ។

ចំពោះស្ថានភាពចាំបាច់វិញ គឺសំដៅទៅលើអំពើណាដែលពុំអាចជៀសវាងបាន ដើម្បីការពាររូបកាយ ឬ ទ្រព្យសម្បត្តិរបស់ខ្លួន ឬ អ្នកដទៃចំពោះគ្រោះថ្នាក់បច្ចុប្បន្ន ឬអច្ចាសន្ន ហើយដែលស្ថិតក្នុងករណីមានតុល្យភាពរវាងវិធីការពារ និងកម្រិតគ្រោះថ្នាក់នោះ។

យោងតាមស្មារតីនៃកថាខណ្ឌ២ នៃមាត្រា ៧៥៦ នៃក្រមរដ្ឋប្បវេណី បានបញ្ជាក់ថាអំពើការពារជាធម្មានុរូប និងអំពើដោយសារស្ថានភាពចាំបាច់ដូចបានកំណត់ខាងលើ បើបានបង្កឲ្យមានការខូចខាតនោះ បុគ្គលដែលប្រព្រឹត្តមិនបាច់ទទួលខុសត្រូវនោះទេ។ បន្ថែមលើនេះទៀត មាត្រាដដែល ក៏បានលើកឡើងពីការរួចផុតពីភាពផ្ទុយច្បាប់ផ្សេងទៀត ដូចជាការយល់ព្រម ឬការទទួលយកគ្រោះថ្នាក់ពីសំណាក់អ្នករងគ្រោះដោយសមហេតុផល និង អំពើបង្កការខូចខាត ដែលត្រូវបានសង្គមទទួលស្គាល់ថាសមហេតុផល។ ប៉ុន្តែអំពើដែលសង្គមទទួលថាសមហេតុផល និងអាចទទួលយកបាននោះ គឺមានលក្ខណៈពិបាកបញ្ជាក់ណាស់ ហើយបញ្ហានេះត្រូវអាស្រ័យទៅលើអត្ថន័យនៃយុត្តិធម៌ ។ ជាទូទៅ អំពើដែលបណ្តាលឲ្យមានការខូចខាតនៅក្នុងប្រភេទកីឡាប៉ះគ្នាដូចជា កីឡាប្រដាល់ ឬ កីឡាបាល់អោប អាចត្រូវបានចាត់ទុកថា ជាសកម្មភាពដែលសង្គមទទួលស្គាល់ ថាសមហេតុផល ។ ប៉ុន្តែលើកលែងតែបុគ្គលដែលបានប្រព្រឹត្តអំពើផ្ទុយច្បាប់ដែលជាមូលហេតុនៃការទទួលខុសត្រូវ ព្រោះសង្គមមិនទទួលស្គាល់ថាសមហេតុផល ។

**ខ. អសមត្ថភាពក្នុងការទទួលខុសត្រូវ**

ទាក់ទងនឹងសមត្ថភាពនេះដែរ ជាគោលការណ៍ក្រមរដ្ឋប្បវេណី បានផ្តល់នូវការការពារជនដែលមានសមត្ថភាពទាប ហើយដែលមិនអាចវិនិច្ឆ័យ និងធ្វើសកម្មភាពតាមលក្ខណៈសមហេតុផល។ ស្តីពីការទទួលខុសត្រូវខាងអំពើអនីត្យានុកូល អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ ឬ ជនដែលមានវិបត្តិផ្នែកស្មារតី រួចផុតពីការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល (មាត្រា ៧៤៥)។

ដូចដែលមានបញ្ជាក់ត្រង់មាត្រា ៧៤៥ កថាខណ្ឌទី២ បុគ្គលដែលមានវិបត្តិផ្នែកស្មារតី គឺត្រូវរួចផុតពីការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល ។ ប៉ុន្តែមិនដូចជាជនដែលស្ថិតនៅក្រោមអាយុ ១៤ ទេ ជនបែបនេះនៅតែត្រូវទទួលខុសត្រូវនៅក្នុងករណី ដែលជននេះ អសមត្ថភាពដោយកំហុសចេតនា ឬ ដោយកំហុសអចេតនានោះ។